## សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំពេញអង្គ

## អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨

## ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨

- សូមគោរពគណៈអធិបតី
- ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា និងរាជធានី-ខេត្ត
- ឯកឧត្តម លោកជំទាវ លោក លោកស្រីមកពីអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា និងរាជធានី-ខេត្ត និង
- អស់លោក-លោកស្រីជាភ្ញៀវជាតិនិងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនាពេលនេះ

ថ្ងៃនេះខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយជាអតិបរមាដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ ២០១៨**" ដ៏មានសារៈសំខាន់នៅពេលនេះ។

ឆ្លៀតក្នុងឱកាសដ៏មហាវិសេសវិសាលនាពេលនេះផងដែរ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំពេញអង្គរបស់យើង។ ជាមួយគ្នានេះ ខ្ញុំក៏សូមឆ្លៀតឱកាសសម្តែងនូវការកោតសរសើរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីដែលបានខិតខំយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីចូលរួមចំណែកដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យប្រយុទ្ធនឹងជំងឺអេដស៍នៅគ្រប់លំដាប់ថ្នាក់រហូតទទួលបានជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ នៅក្នុងរយៈពេល៦ខែចុងឆ្នាំ២០១៨នេះ តាមរយៈការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលប្រកបដោយចីរភាព ដែលនាំមកនូវសមិទ្ធផលគួរជាទីមោទនៈ ដែលអាចត្រួតពិនិត្យបាននូវរាលដាលមេរោគអេដស៍នៅកម្ពុជាឱ្យធ្លាក់ចុះជាបន្តបន្ទាប់។

ខ្ញុំសូមអនុញ្ញាតជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមគម្រោងផែនការសកម្មភាពឆ្នាំ ២០១៨ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវប្រារព្ធឡើងជាទៀងទាត់រៀងរាល់៦ខែម្តង ដូច្នេះកិច្ចប្រជុំនាថ្ងៃនេះគឺជាកិច្ចប្រជុំលើកទី២បញ្ចប់ឆ្នាំ២០១៨ ដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពនៃការឆ្លើយតបប្រយុទ្ធនឹងជំងឺអេដស៍៦ខែចុងឆ្នាំ២០១៨ រួមជាមួយនឹងការពិភាក្សាទៅលើចំណុចខ្វះខាតមួយចំនួន ដែលត្រូវការនូវដំណោះស្រាយតាមរយៈការចូលរួមរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលមានវត្តមាននៅពេលនេះ។ លើសពីនេះអង្គប្រជុំនេះនឹងមានដាក់ចេញនូវសេចក្តីសម្រេច ដែលជាគោលការណ៍សម្រាប់យកទៅប្រើប្រាស់បន្តក្នុងការអនុវត្តផែនការសកម្មភាពគន្លឹះនៅឆ្នាំ២០១៩។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី**

យោងតាមរបៀបវារៈសម្រាប់កិច្ចប្រជុំនៅថ្ងៃនេះ គឺនឹងមានការបង្ហាញមួយចំនួន ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ស្តីពី ករណីវិនិយោគសម្រាប់សង្គមស៊ីវិល និងការសិក្សាពីការគ្របដណ្តប់មូលនិធិសមធម៌លើអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ និងផែនទីបង្ហាញផ្លូវ ដើម្បីជានានិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា និងលទ្ធផលនៃការពិនិត្យឡើងវិញផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ ដើម្បីផ្តល់ជូនដល់អង្គពិធីទាំងមូលបានជ្រាបច្បាស់ពីការវិនិយោគរបស់សង្គមស៊ីវិលក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងផែនទីបង្ហាញផ្លូវក្នុងការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាពីឆ្នាំ២០១៩ ដល់២០២៣។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមទាញអារម្មណ៍អង្គប្រជុំថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជាគោលការណ៍ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការលុបបំបាត់ជំងឺអេដស៍ តាមរយៈការកំណត់យ៉ាងច្បាស់លាស់នូវគោលដៅសូន្យបីគឺ "គ្មានការឆ្លងជំងឺអេដស៍ថ្មី" "គ្មានការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍" និង "គ្មានការស្លាប់ដោយសារជំងឺអេដស៍" នៅត្រឹមឆ្នាំ២០២៥ ដោយត្រៀមគោលដៅ៩០-៩០-៩០ ទាំងស្រុងនៅឆ្នាំ២០២០ និងគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។

ជារួម ប្រទេសកម្ពុជាយើងកំពុងតែឈរនៅលើផ្លូវត្រូវ យើងកំពុងតែធ្វើត្រូវក្នុងក្តីសង្ឃឹមពិតប្រាកដឆ្ពោះទៅរកការលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ ដោយសារតែប្រទេសកម្ពុជាយើងមានកត្តាចាំបាច់ដ៏មានប្រសិទ្ធភាពខ្ពស់រួចទៅហើយ គឺការប្តេជ្ញាចិត្តគាំទ្រជានយោបាយដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រួមជាមួយនឹងកត្តាគ្រប់គ្រាន់មួយចំនួនគឺ ៖ មានចីរភាពនៃការចូលរួមឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល ឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។ល។ មានប្រព័ន្ធ

តាមដានការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍បានជាប្រចាំ មានស្ថាប័នដឹកនាំ គ្រប់គ្រង និង សម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានផែនការយុទ្ធសាស្ត្រជាតិតែមួយ និងមានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដូច្នេះអ្វីដែលកម្ពុជានៅសេសសល់ដើម្បីសម្រេចបាននូវក្តីសង្ឃឹមខាងលើ គឺកម្ពុជានៅកំពុងប្រឈមនឹងបញ្ហាធនធានតែប៉ុណ្ណោះ គឺធនធានមនុស្សដែលទាមទារនូវការកសាងសមត្ថភាពពេញលេញពីយុទ្ធសាស្ត្រវិទ្យាសាស្ត្រថ្មីៗក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ធនធានសម្ភារបរិក្ខារក្នុងការប្រើប្រាស់បច្ចេកវិជ្ជាអ៊ីនធឺណែត និងធនធានថវិកាដែលជាបញ្ហាប្រឈមខ្ពស់ជាងគេ។ ដូច្នេះ ទាមទារនូវការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក-លោកស្រីប្រើប្រាស់គ្រប់លទ្ធភាពទាំងអស់ ក្នុងការចលនាធនធានពីគ្រប់ប្រភពទាំងអស់ រួមជាមួយនឹងការធានាដល់ការចំណាយធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយចៀសវាងឱ្យបាននូវការចំណាយច្រើនទទួលបានផលតិច ឬការចំណាយជាន់គ្នា។ល។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី**

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះពិតជាមានសារៈសំខាន់ណាស់ដែលផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តការរៀបចំ និងអនុវត្តការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នាឆ្នាំ២០១៩ឱ្យបានសមស្របទៅនឹងអនុសាសន៍ដែលបានផ្តល់ជូនពីសម័យប្រជុំពេញអង្គនៅពេលនេះ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនសម្រាប់ការពិភាក្សា ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នាពេលនេះ និងសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក-លោកស្រីទាំងអស់ឱ្យមានសុខភាពល្អ កម្លាំងមាំមួនក្នុងការចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨**” ចាប់ពីពេលនេះតទៅ។

**សូមអរគុណ៕**